ល.រ៖ អង្គការថែរ ២០២៣/.០៧៦...

CARE Cambodia
(3rd floor), #39, Street 352
Sangkat Boeung Keng Kang 1,
Khan Boeung Keng Kang,
Phnom Penh, 12302
Tel: +855 (0) 23 727 145/7/8
Email: khm.info@careint.org
care-cambodia.org

**សូមគោរពជូន**
**លោកជំទាវ ជូ ប៊ុនអេង**
**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍**
**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

កម្មវត្ថុ៖ សំណើសុំគោរពអញ្ជើញ **លោកជំទាវ** ចូលរួមជាគណៈអធិបតីក្នុងកម្មវិធីកិច្ចសន្ទនាជាន់ខ្ពស់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗនៃគម្រោង «ធ្វើឱ្យកន្លែងធ្វើការមានសុវត្ថិភាព និងមានការគោរពនៅក្នុងឧស្សាហកម្មកាត់ដេរ» របស់អង្គការថែរអន្តរជាតិប្រចាំកម្ពុជា នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៩ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមអនុញ្ញាតជម្រាបជូន **លោកជំទាវ** មេត្តាជ្រាបថា អង្គការថែរអន្តរជាតិប្រចាំកម្ពុជាបាននឹងកំពុងអនុវត្តកម្មវិធីស្ត្រីបាត់បង់ឱកាសនៅក្នុងទីក្រុងតាមរយៈគម្រោង «**ធ្វើឱ្យកន្លែងធ្វើការមានសុវត្ថិភាព និងមានការគោរពនៅក្នុងឧស្សាហកម្មកាត់ដេរ**» ដើម្បីលើកកម្ពស់ការលុបបំបាត់ការបៀតបៀននៅក្នុងខ្សែរសង្វាក់ផ្គត់ផ្គង់ និងការជះឥទ្ធិពលទៅលើការផ្លាស់ប្តូរឧស្សាហកម្ម និងដើម្បីឲ្យកម្មការិនីទាំងអស់មានអារម្មណ៍សុវត្ថិភាព និងទទួលបាននូវការគោរពនៅកន្លែងធ្វើការ។ កម្មវិធីកិច្ចសន្ទនាជាន់ខ្ពស់នេះ មានគោលបំណងដើម្បីពង្រឹងការយល់ដឹង ការប្តេជ្ញាចិត្ត និងសកម្មភាពដើម្បីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀននៅក្នុងឧស្សាហកម្មកាត់ដេរ និងដើម្បីកំណត់ការខិតខំប្រឹងប្រែងរួមគ្នាពី ភាគីពាក់ព័ន្ធក្នុងការគាំទ្រការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សានិងការបៀតបៀនក្នុងពិភពការងារ របស់អង្គការអន្តរជាតិខាងការងារ និងការទទួលយកការអនុវត្តយ៉ាងទូលំទូលាយនូវគោលការណ៍ណែនាំស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀននៅក្នុងឧស្សាហកម្មកាត់ដេរ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកជំទាវ** មេត្តាពិនិត្យតាមសំណើដោយក្តីអនុគ្រោះ។
សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីនាងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣

**នាយិកាប្រចាំប្រទេស**

**នៅ សុមន្ត្រា**

កំណត់សម្គាល់៖
ទំនាក់ទំនងតាមរយៈ លោកស្រី ជួន ដាវីត
០១៧ ២៣១ ០៨៧/០៨៦ ៩៤១ ៧៨២

Scanned with CamScanner

PRIMARK

care

# ទស្សនៈទាន

# កិច្ចសន្ទនាជាន់ខ្ពស់ ស្ដីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន នៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា

## ទិដ្ឋភាពទូទៅ

កម្មករនិងកម្មការិនីដែលធ្វើការលើវិស័យកាត់ដេរនៅកម្ពុជា មានប្រមាណ ៦០ម៉ឺននាក់ ហើយ ៨៥% គឺជាស្ត្រី។ កម្មករភាគច្រើនបានផ្លាស់ទីពីជនបទមករកការងារធ្វើនៅទីក្រុង។ ការស្រាវជ្រាវរបស់ អង្គការឃែរ បានរកឃើញថា ៩៧% នៃអ្នកដែលធ្វើការក្នុងទីក្រុងភ្នំពេញ គឺជាជនចំណាកស្រុកក្នុងប្រទេស។ ការងារក្នុងវិស័យកាត់ដេរគឺជាឱកាសមួយសម្រាប់ការពង្រឹងដល់សេដ្ឋកិច្ចប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការងារដែលប្រកបដោយសេចក្តីថ្លៃថ្នូរអាចធ្វើទៅបានលុះត្រាតែមានការគោរពសិទ្ធិមនុស្ស និងសិទ្ធិការងារ។ ថ្វីបើមានអត្រាចូលរួមខ្ពស់ក្នុងឧស្សាហកម្មកាត់ដេរក៏ដោយ ក៏ស្ត្រីមិនបានស្ថិតក្នុងលក្ខខណ្ឌស្មើគ្នាជាមួយមិត្តរួមការងារជាបុរសរបស់ពួកគេដែរ ហើយស្ត្រីទាំងនោះមានការប្រឈមខ្ពស់ទៅលើការបៀតបៀនផ្លូវភេទនៅកន្លែងការងារ។ បទដ្ឋានយេនឌ័រដែលបន្តបង្កឱ្យកើតមានវិសមភាពរវាងស្ត្រី និងបុរសនៅកន្លែងការងារ ត្រូវតែធ្វើការដោះស្រាយ ដើម្បីធានាបានការចូលរួមយ៉ាងពេញលេញពីស្ត្រី។

មកដល់ឆ្នាំ ២០២២ រោងចក្រជាង ៤០ នៅក្នុងប្រទេសកម្ពុជាបានទទួលការគាំទ្របច្ចេកទេសពី អង្គការឃែរ ដើម្បីដោះស្រាយបញ្ហានៅកន្លែងធ្វើការដោយប្រើប្រាស់នូវគំរូរបស់កម្មវិធី បញ្ឈប់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ (STOP) របស់អង្គការឃែរ ដែលគំរូនៃគម្រោងនៅក្នុងតំបន់ដើម្បីលើកកម្ពស់ការការពារនិង ទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ដែលរួមបញ្ចូលទាំងគោលនយោបាយ ការណែនាំ និងកញ្ចប់បណ្តុះបណ្តាលសម្រាប់កម្មករដើម្បីការពារ និងទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងការងារ។ ដើម្បីផ្តល់នូវនីតិវិធីប្រតិបត្តិការច្បាស់លាស់នៅក្នុងការកំណត់ថារោងចក្របានធ្វើតាមស្តង់ដារក្នុងការកសាង វិធីសាស្ត្រជាប្រព័ន្ធ និងនិរន្តរភាពក្នុងការដោះស្រាយបញ្ហាទាំងនេះ អង្គការឃែរ និង គម្រោងរោងចក្រកាត់ដេរកាន់តែប្រសើរនៅកម្ពុជា (ILO/BFC) បានសហការបង្កើតនូវគោលការណ៍ណែនាំស្តង់ដារមួយ សម្រាប់អាជីវកម្មទាំងអស់នៅក្នុងខ្សែរសង្វាក់ផ្គត់ផ្គង់សម្លៀកបំពាក់ ដើម្បីធ្វើការដោះស្រាយបញ្ហាដូចជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន។ គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់អាជីវកម្មឱ្យធ្វើការចាត់វិធានការប្រកបដោយអត្ថន័យ និងមានប្រសិទ្ធភាពដើម្បីធានាឱ្យបានថាកម្មករ និងកម្មការិនីមានសុវត្ថិភាព និងទទួលបានការគោរព នៅគ្រប់ជាន់នៃខ្សែរសង្វាក់ផ្គត់ផ្គង់។

នៅខែមិថុនា ឆ្នាំ ២០២២ អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា បានសហការជាមួយ ILO/BFC បានរៀបចំកិច្ចសន្ទនាជាន់ខ្ពស់ជាមួយក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតដូចជាតំណាងសមាគមវាយនភ័ណ្ឌ

CS Scanned with CamScanner

សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរនៅកម្ពុជា (TAFTAC) ម្ចាស់ម៉ាក អ្នកដឹកនាំ/អ្នកគ្រប់គ្រងរោងចក្រ និងអង្គការសង្គមស៊ីវិលមួយចំនួនដើម្បីចែករំលែកការរៀនសូត្រ និងការអនុវត្តទាក់ទងនឹងការទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។ លទ្ធផលនៃការសន្ទនាទាំងនេះរួមមានការផ្តល់មតិយោបល់សំខាន់ៗពីអ្នកចូលរួមដូចខាងក្រោម៖

- អង្គការឃែរ និង ILO/BFC បានបន្តតាមដានវឌ្ឍនភាពរោងចក្រក្នុងការអនុវត្តគម្រោងទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។ ជំរុញឱ្យរោងចក្រថ្មីអនុវត្តគម្រោងនេះ និងផ្តល់វគ្គបណ្តុះបណ្តាលបន្ថែម និងពង្រីកគម្រោងនេះឱ្យមានផលជះជាវិជ្ជមានកាន់តែខ្លាំង។
- អង្គការឃែរ បានជួយសម្រួលដល់សិក្ខាសាលាពិគ្រោះយោបល់ដែលកំពុងបន្តជាមួយរដ្ឋាភិបាល និយោជក និងតំណាងនិយោជិត ម្ចាស់ម៉ាក/អ្នកទិញ និងអង្គការសង្គមស៊ីវិល ដើម្បីធ្វើការពិភាក្សាឱ្យមានការឆ្ពោះទៅមុខបន្តទៀតនៅជាន់ខ្ពស់ជាងមុន។
- អង្គការឃែរ ចូលរួមជាមួយនឹងបុរសដើម្បីការពារ និងដោះស្រាយបញ្ហានេះ។
- អង្គការឃែរ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធមួយចំនួនបានរួមគ្នាធ្វើសេចក្តីប្រកាសជាមួយនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងកិច្ចការនារី អំពីការទប់ស្កាត់ការបៀតបៀនផ្លូវភេទ និងអំពើហិង្សានៅក្នុងរោងចក្រ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការយេនឌ័រនៃ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបានលទ្ធផលជាវិជ្ជមានកាន់តែប្រសើរឡើងបន្ថែមទៀត។

បច្ចុប្បន្ននេះ អង្គការឃែរ បាននិងកំពុងធ្វើការអនុវត្តគម្រោងរយៈពេល ១៨ខែ គឺគម្រោង **"ធ្វើឱ្យកន្លែងធ្វើការមានសុវត្ថិភាព និងមានការគោរពនៅក្នុងឧស្សាហកម្មកាត់ដេរ"** ជាមួយនឹងរោងចក្រគោលដៅចំនួន ៥ ដែលបានចាប់ផ្តើមនៅខែធ្នូ ឆ្នាំ ២០២១ ដល់ខែឧសភា ឆ្នាំ ២០២៣។ គម្រោងនេះមានគោលបំណងលើកកម្ពស់ការលុបបំបាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងឧស្សាហកម្មដែលមានឥទ្ធិពលផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីឱ្យកម្មករ និងកម្មការិនីទាំងអស់មានអារម្មណ៍មានសុវត្ថិភាព និងទទួលបានការគោរពនៅកន្លែងធ្វើការ។ រោងចក្រគោលដៅបានអនុម័តយ៉ាងសកម្មនូវគោលការណ៍ទប់ស្កាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការនិងទទួលបានការបណ្តុះបណ្តាលបច្ចេកទេសជាបន្តបន្ទាប់ និងការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាលផ្សេងៗ ដើម្បីអនុវត្តគោលការណ៍ប្រកបដោយប្រសិទ្ធភាពពីអង្គការឃែរ។ គម្រោងនេះគ្រោងនឹងរៀបចំកិច្ចសន្ទនាជាន់ខ្ពស់មួយ ជាមួយភាគីពាក់ព័ន្ធសំខាន់ៗដែលមានអ្នកចូលរួមប្រមាណ៦០នាក់។ កិច្ចសន្ទនានេះ មានគោលបំណងដើម្បីជម្រុញបន្តការប្តេជ្ញាចិត្តពីកិច្ចសន្ទនាកាលខែមិថុនា ឆ្នាំ ២០២២ តាមរយៈការបង្កើនការចូលរួមជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីកែលម្អលក្ខខណ្ឌសម្រាប់ស្ត្រីដែលធ្វើការក្នុងឧស្សាហកម្មកាត់ដេរ។

Scanned with CamScanner

PRIMARK care

## គោលបំណងកម្មវិធី

- មានគោលបំណងដើម្បីពង្រឹងការយល់ដឹង ការប្តេជ្ញាចិត្ត និងសកម្មភាពដើម្បីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន នៅក្នុងឧស្សាហកម្មកាត់ដេរ។
- ដើម្បីកំណត់ការខិតខំប្រឹងប្រែងរួមគ្នាពីភាគីពាក់ព័ន្ធ ក្នុងការគាំទ្រការ ផ្តល់សច្ចាប័នលើ អនុសញ្ញាលេខ ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សានិងការបៀតបៀនក្នុងពិភពការងារ របស់អង្គការអន្តរជាតិខាងការងារ និងការទទួលយកការអនុវត្តយ៉ាងទូលំទូលាយនូវគោលការណ៍ណែនាំ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀននៅក្នុងឧស្សាហកម្មកាត់ដេរ។

**កាលបរិច្ឆេទ៖** ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ ចាប់ពីម៉ោង៨.៣០ ដល់ម៉ោង១២ថ្ងៃត្រង់

**ទីកន្លែងកម្មវិធី៖** សណ្ឋាគារហ៊ីម៉ាវ៉ារី

**អ្នកចូលរួម៖** ប្រមាណ ៥០ នាក់

**របៀបវារៈ៖**

| | |
|---|---|
| ០៨:៣០ - ០៩:០០ | ការចុះឈ្មោះ និងការជួបជុំ |
| ០៩:០០ - ០៩:១០ | មតិស្វាគមន៍ដោយ **លោកស្រី នៅ សុខត្លា, នាយិកាប្រចាំប្រទេសអង្គការថែរក្សាអន្តរជាតិប្រចាំកម្ពុជា** |
| ០៩:១០ - ០៩:២០ | សុន្ទរកថាបើកដោយ **លោកជំទាវ សុខណ្ណ ចណ្ណារតន៍ រដ្ឋលេខាធិការនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** |
| ០៩:២០ - ០៩:៣៥ | ការបង្ហាញសង្ខេបពីគោលការណ៍ណែនាំ ស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀន |
| ០៩:៣៥ - ០៩:៥០ | ចែករំលែកវឌ្ឍនភាពនៃការអនុវត្តគោលការណ៍ ទប់ស្កាត់ការបៀតបៀនផ្លូវភេទ ដោយអ្នកគ្រប់គ្រងរោងចក្រ<br>សំណួរ-ចម្លើយ |
| ០៩:៥០ – ១០:០៥ | សម្រាកអាហារសម្រន់ |
| ១០:០៥ - ១០:១៥ | សំឡេងរបស់កម្មកររោងចក្រស្តីពីការអនុវត្តល្អរបស់រោងចក្រ/ការព្រួយបារម្ភលើ ការទប់ស្កាត់ការបៀតបៀនផ្លូវភេទ |
| ១០:១០ – ១០:៣៥ | បទបង្ហាញសង្ខេបស្តីពីអនុសញ្ញា ILO លេខ១៩០ (ILO C-190) ដោយតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១០:៣៥ - ១១:៤០ | កិច្ចសន្ទនាស្តីពីដំណើរការនៃការគាំទ្រឱ្យមានការផ្តល់សច្ចាប័នលើ ILO-C190 នៅកម្ពុជា |

CS Scanned with CamScanner

វាគ្មិន៖ តំណាងមកពី

១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

២. ក្រសួងកិច្ចការនារី

៣. មជ្ឈមណ្ឌលសាមគ្គីភាព

៤. ម្ចាស់ហាង

៥. រោងចក្រ ខ្សែសង្វាក់ផ្គត់ផ្គង់

៦. សហជីព

អ្នកសម្របសម្រួល៖ អង្គការឃែរ

សំនួរ-ចម្លើយ

១១:៤០ – ១១:៥០ សង្ខេបលទ្ធផលទទួលបាន

១១:៥០ – ១២:០០ សុន្ទរកថាបិទកម្មវិធីដោយ **លោកជំទាវ ហ៊ឺ សាមិត្ត រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី**

*កម្មវិធីអាចកែប្រែក្នុងករណីចាំបាច់។*

CS Scanned with CamScanner